ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំប្រទេសជប៉ុន

# សេចក្ដីប្រកាសព័ត៌មាន

## ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសជប៉ុន ជួបពិភាក្សាអំពីកិច្ចសហប្រតិបត្តិការ ជាមួយសាកលវិទ្យាល័យវេជ្ជសាស្ត្រតូហូគី

នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៦ **ឯកឧត្តម ជុំ សុន្ទរី** ឯកអគ្គរាជទូតតែងតាំងនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសជប៉ុន បានអញ្ជើញទទួលជួបគណៈប្រតិភូមកពីសាកលវិទ្យាល័យវេជ្ជសាស្ត្រតូហូគី ដែលដឹកនាំដោយលោកសាស្ត្រាចារ្យ Katsushiro Yamaguchi ប្រធានក្រុមហ៊ុនវេជ្ជសាស្ត្រ Gyoukoukai និងជាប្រធានមន្ទីរព្យាបាលចក្ខុសាស្ត្រ Ohashi Eye Clinic។ ជំនួបនេះ ត្រូវបានរៀបចំឡើងដោយ ឯកឧត្តម TAI Susumu កុងស៊ុលកិត្តិយសកម្ពុជាប្រចាំតំបន់សេនដាយ និងជាទីប្រឹក្សា **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងតូក្យូ។

ក្នុងជំនួប ភាគីទាំងពីរបានផ្លាស់ប្តូរទស្សនៈជុំវិញការពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងជប៉ុន ជាពិសេសក្នុងវិស័យសុខាភិបាល និងការអភិវឌ្ឍធនធានមនុស្ស។ **ឯកឧត្តមឯកអគ្គរាជទូត** បានសម្តែងការកោតសរសើរយ៉ាងជ្រាលជ្រៅចំពោះការចូលរួមដ៏យូរអង្វែងរបស់លោកសាស្ត្រាចារ្យ Katsushiro Yamaguchi ជាមួយប្រទេសកម្ពុជា រួមទាំងការចូលរួមផ្នែកមនុស្សធម៌ចំពោះប្រជាជនកម្ពុជាផងដែរ។

ទន្ទឹមនឹងនេះ **ឯកឧត្តមឯកអគ្គរាជទូត** បានលើកឡើងពីតួនាទីដ៏សំខាន់របស់ ឯកឧត្តម TAI Susumu ក្នុងការជម្រុញកិច្ចសហប្រតិបត្តិការក្នុងវិស័យវេជ្ជសាស្ត្ររវាងកម្ពុជា និងជប៉ុន។ លើសពីនេះ **ឯកឧត្តមឯកអគ្គរាជទូត** បានថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះសាកលវិទ្យាល័យវេជ្ជសាស្ត្រតូហូគី សម្រាប់កិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នវេជ្ជសាស្ត្រកម្ពុជា។

ក្នុងន័យនេះ វេជ្ជបណ្ឌិតផ្នែកចក្ខុសាស្ត្រកម្ពុជាចំនួន ២រូប មកពីមន្ទីរពេទ្យកាល់ម៉ែត រួមមានលោកវេជ្ជបណ្ឌិត អឿន សុបញ្ញាតូ និងលោកវេជ្ជបណ្ឌិត វ៉េត សានហ៊ី ត្រូវបានអញ្ជើញមកចូលរួមកម្មវិធីបណ្តុះបណ្តាលនៅសាកលវិទ្យាល័យវេជ្ជសាស្ត្រតូហូគី ពីថ្ងៃទី២៦ កុម្ភៈ ដល់ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦។ កម្មវិធីនេះបានផ្តល់ឱកាសដ៏មានតម្លៃដល់វេជ្ជបណ្ឌិតកម្ពុជាក្នុងការលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈរបស់ខ្លួន។ **ឯកឧត្តម**

8-6-9 AKASAKA, MINATO-KU, TOKYO 107-0052
Tel : +81 3-5412-8521 Fax: +81 3-5412-8526
Email: camemb.jpn@mfaic.gov.kh

**ឯកអគ្គរាជទូត** បានសម្តែងទុំនុកចិត្តថាគំនិតផ្តួចផ្តើមក្នុងការបង្កើតកម្មវិធីបណ្តុះបណ្តាលនេះ នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់គុណភាពសេវាសុខាភិបាលនៅកម្ពុជា។

ក្នុងជំនួប ភាគីទាំងពីរបានផ្លាស់ប្តូរទស្សនៈជុំវិញការបន្តកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីជម្រុញបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការក្នុងវិស័យសុខាភិបាល និងការអភិវឌ្ឍធនធានមនុស្សរវាងប្រទេសទាំងពីរ។ **ឯកឧត្តមឯកអគ្គរាជទូត** បានបញ្ជាក់ជាថ្មី អំពីការត្រៀមខ្លួនរបស់ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងតូក្យូ ក្នុងការគាំទ្រ និងសម្របសម្រួលកិច្ចសហការរវាងស្ថាប័នវេជ្ជសាស្ត្រកម្ពុជា និងជប៉ុន ដើម្បីពង្រឹងបន្ថែមនូវទំនាក់ទំនងរវាងកម្ពុជា-ជប៉ុន ជាពិសេសលើវិស័យសុខាភិបាល និងការអភិវឌ្ឍធនធានមនុស្ស។

ថ្ងៃសុក្រ ២កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

តូក្យូ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦